## ជម្លោះប្រដាប់អាវុធអន្តរជាតិ (international armed conflict)

ពាក្យនេះ ត្រូវបានប្រើនៅក្នុងមាត្រា ២ រួម (common article 2) នៃអនុសញ្ញាហ្សឺណែវឆ្នាំ ១៩៤៩ (GC I) ក្នុងខ្លឹមសារថា *ជាសង្គ្រាមត្រូវបានប្រកាស ឬជម្លោះប្រដាប់អាវុធផ្សេងទៀត ដែលកើតមានរវាងរដ្ឋពីរ ឬច្រើន ទោះបីស្ថានភាពនៃសង្គ្រាម មិនត្រូវបានទទួលស្គាល់ ដោយភាគីម្ខាងណាមួយក្តី*។

តាមអត្ថន័យនេះ វាមានធាតុផ្សំចំនួនពីរ៖១. មានរដ្ឋចាប់ពីពីរឡើងទៅចូលរួម និងទី២ គឺការទទួលស្គាល់សង្គ្រាម ទោះបីតាមព្រឹត្តន័យ (*de facto* of State of war) ដើម្បីមិនឲ្យមានលេសមិនអនុវត្តវិធានច្បាប់មនុស្សធម៌។

រយៈពេល វិសាលភាព ឬចំនួនកងកម្លាំងចូលរួមប៉ុន្មាននាក់ មិនជាបញ្ហាចម្បងទេ។ ជាក់ស្តែងសង្គ្រាមអន្តរជាតិខ្លះ កើតមានតែនៅក្នុងតំបន់ក្បែរព្រំដែន។ ក្នុងករណីអតីតយូហ្គោស្លាវី សង្គ្រាមកើតក្នុងរដ្ឋតែមួយ ក៏ប៉ុន្តែមានការចូលរួមពីកងកម្លាំងនៃរដ្ឋផ្សេងទៀត ត្រូវបានចាត់ចូលក្នុងនិយមន័យនេះ (*Tadic*, IT-94-1, AC, 2 Oct 1995, S. 70)។

បញ្ហានិយមន័យ មានភាពស្មុគស្មាញ នៅពេលគេយោងដល់ឈ្មោះសង្គ្រាម បង្កើតដោយរដ្ឋខ្លះ (war on terror) ក្រោយព្រឹត្តិការណ៍ ១១ កញ្ញា ២០០១ ដូចជាសង្គ្រាមរវាង អ៊ីស្រាអែល និងក្រុម Hezbollah ដែលកើតក្នុងដែនដីចំនួនពីរ ក៏ប៉ុន្តែគូរជម្លោះម្ខាង គឺជាក្រុមកងកម្លាំងមិនមែនរបស់រដ្ឋ។ ទោះបីជាមានភាពស្រពិចស្រពិលយ៉ាងនេះក្តី យុត្តិសាស្ត្រ បានបង្ហាញអំពីការឯកភាពលើការអនុវត្តវិធានអប្បបរមាក្នុងមាត្រា៣រួម (common article 3)។

ឆ្លើយតបនឹងបញ្ហាចោទអំពីប្រភេទនៃសង្គ្រាម និងវិធានត្រូវអនុវត្ត ក្បួនសឹករបស់ប្រទេស អាឡឺម៉ង់ និង អ៊ីតាលី បានចែងតម្រូវថា យ៉ាងហោចណាស់វិធានមួយចំនួន ត្រូវអនុវត្តជារួម ចំពោះជម្លោះទាំងពីរប្រភេទ (Antonio Cassese, the Oxford Companion to International Criminal Justice, 2009, pp. 382-383)។